# Living the Lotus 11

## Buddhism in Everyday Life

2025
VOL. 242

### Overseas Members Cheerfully Participate in the 2025 Oeshiki-Ichijo Festival in Tokyo

















Living the Lotus
Vol. 242 (November 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President's Message*

# យើងនាំគ្នាប្រគុំតន្ត្រីសុខដុមរមនា①
# ការបែកបាក់និងភាពសុខដុមរមនា

ដោយព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## យើងគ្មានកន្លែងទៅទេ

ខែនេះជាខែធ្វើបុណ្យរំលើកខួបកំណើតព្រះស្ថាបនិកកៃសូសាម៉ាដែលតែងតែប្រាថ្នាភាពសុខដុមរមនារបស់មនុស្សជាតិនិងសន្តិភាពពិភពលោកតាំងតែពីព្រះអង្គលោកចាប់ផ្តើមបង្កើតសមាគមយើងនេះមកម្ល៉េះ។កាលនោះទោះបីជាលោកចូលដល់វ័យ៨៨វស្សាដូចខ្ញុំព្រះករុណាអាត្មាភាពសព្វថ្ងៃនេះក្តីក៏លោកតែងតែនិយាយយ៉ាងក្លៀវក្លាថា៖អាត្មាភាពចង់ធ្វើទានអាយុជីវិតដែលកំពុងតែរស់នៅនេះដល់មនុស្សទាំងឡាយ។

ក៏ប៉ុន្តែនៅសម័យកាលណាក៏ដូចជាសម័យកាលណា មនុស្សយើងកាលណាមានអ្វីដែលប្រព្រឹត្តទៅមិនបានដូចចិត្តប្រាថ្នារបស់ខ្លួន តែងតែមួរម៉ៅក្តៅក្រហាយស្អប់មនុស្សដែលប្រឆាំងនឹងគំនិតយោបល់ខ្លួនឬក៏ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនគេទៅជាមិនរវីរវល់អើពើពីភាពសុខដុមរមនាហើយផ្តួលរំលំគូបដិបក្ស អ្នកខ្លះទៀតរហូតដល់មិនខ្វល់ខ្វាយនឹងការបែកបាក់ប្រេះឆានៃប្រទេសជាតិឬសង្គមជាតិទៅទៀត។ជាពិសេសបើសម្លឹងមើលទៅពិភពលោកបច្ចុប្បន្ននេះនៅកន្លែងនេះកន្លែងនោះយើងឃើញថាមនុស្សភ្លេចអស់នូវអ្វីដែលជាសារៈសំខាន់ក្នុងនាមជាមនុស្ស។

សារៈសំខាន់ក្នុងនាមជាមនុស្សចម្បងគេគឺគោលការណ៍ដែលយើងទាំងអស់គ្នាត្រូវបានថែរក្សាឱ្យបានបន្តរស់រានមានជីវិតនិងពង្រស់អ្នកដទៃឱ្យបានរស់នៅជាមួយគ្នាតាមរយៈទំនាក់ទំនងហេតុនិងផលគ្រប់ប្រភេទ។

អតីតអវកាសយានិកជនជាតិអាមេរិកដែលខ្ញុំព្រះករុណាអាត្មាភាពធ្លាប់បានចូលរួមស្តាប់ការបង្រៀនរបស់លោកម្តងគឺលោកស្វាយខាត (Schweickart) បាននិយាយថា"នៅពេលដែលមនុស្សម្នាក់បានទៅស្គាល់អាវ កាស ពួកគេមិនអាចនៅជាមនុស្សដដែលដូចពីមុននោះទេ" ។ អវកាសយានិកាជនជាតិជប៉ុនអ្នកនាង យ៉ាម៉ាហ្សាគី ណាអូកុ (Naoko Yamazaki) បានអះអាងថាពាក្យលោកស្វាយខាតពិតជាត្រឹមត្រូវដោយនាងពណ៌នាអំពីសោភ័ណភាពនៃផែនដីដែលនាងបានឃើញពីលំហអាកាសនិងភាពដ៏គួរឱ្យស្រឡាញ់ជាប់ចិត្តរបស់ផែនដីដែលនាងទទួលអារម្មណ៍នៅពេលត្រឡប់មកវិញដោយនាងបាននិយាយថា"អ្វីគ្រប់យ៉ាងនៅលើផែនដីនេះទ្រទ្រង់ដោយតុល្យភាពផ្សេងៗ" "នោះហើយជាមូលហេតុដែលគួរឱ្យសោក

ស្តាយណាស់នៅពេលដែលមនុស្សឈ្លោះប្រកែកគ្នា។បើយើងមើលពីលំហអាកាស ផែនដីគឺពិតជាយានអវកាស មួយ" (Chugai Nippo, ថ្ងៃទី 27 ខែមករា ឆ្នាំ 2016)។

លោកស៊ីឡា (Schiller) ដែលជាអវកាសយានិកទីមួយរបស់អាមេរិកបាននិយាយថា"ខ្ញុំបានចាកចេញពីផែនដីបីដង ប៉ុន្តែគ្មានកន្លែងណាផ្សេងទៀតដែលខ្ញុំអាចទៅនៅទេ។ សូមអ្នកទាំងអស់គ្នាមេត្តាគោរពអាណិតយានអាវកាសផែនដី ( Spaceship Earth) ផង។គឺជាប្រសាសន៍ដែលចង្អុលប្រាប់យើងនូវរឿងសំខាន់ដែលយើងត្រូវតែចាប់ភ្លឹកនៅពេលនេះ។ ប្រសិនបើយើងធ្វើបាបគ្នាទៅវិញទៅមកវាជាការរំខានដល់ភាពសុខដុមរមនា វានឹងកាន់តែបំផ្លាញសណ្តាប់ធ្នាប់ និងបរិស្ថានពិភពលោក ហើយនាំទៅដល់ការបំផ្លាញខ្លួនឯងផ្ទាល់ដែលជាមនុស្សជាតិ។

## ចូរចងចាំពាក្យថាបំភ្លឺខ្លួនឯងដោយពន្លឺខ្លួនឯងនិងដោយពន្លឺនៃព្រះធម៌

ប្រសិនបើយើងបង្ហាញរូបថតនៃផែនដីដែលមើលឃើញពីលំហអាកាសដល់អ្នកដឹកនាំនៃប្រទេសនានាក្នុងពិភពលោក ហើយបំផុសចិត្តពួកគេឱ្យដឹងពីកន្លែងដែលជីវិតរបស់យើងចេញដំណើរមកនិងពីទានធន្ទៈដែលប្រោសប្រាណឱ្យជីវិតយើងបានរស់នៅតើអាចទេថានឹងមានមនុស្សមួយចំនួនចេះគិតថា "មិនដឹងជាធ្វើសង្គ្រាមរកខ្មោចយក៏អីទេវើយ"ទេ។តើគំនិតនេះវាមិនសុទិដ្ឋិនិយមពេកទេឬ?

យ៉ាងហោចណាស់ក៏យើងទាំងឡាយដែលបានសិក្សាការបង្រៀនប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធពុទ្ធបានរៀនមិនត្រឹមតែអំពីសារៈសំខាន់នៃផែនដីប៉ុណ្ណោះទេក៏ប៉ុន្តែក៏បានរៀនពីការជៀសវាងជម្លោះនិងការបែកបាក់ហើយនិងពីភាពសុខដុមរមនា។

យើងបានរៀនថាបាតុភូតទាំងអស់សុទ្ធតែមានលក្ខណៈបណ្តោះអាសន្ន (ភាពមិនស្ថិតស្ថេរ)ហើយថាអ្វីៗទាំងអស់កើតឡើងតាមរយៈការភ្ជាប់គ្នា អ្វីៗមាននៅក្នុងទំនាក់ទំនងពឹងពាក់គ្នាទៅវិញទៅមក (ភាពគ្មានខ្លួនឯង ឬភាពទទេ) ប្រសិនបើយើងដឹងការពិតទាំងនេះ ហើយចាប់ភ្លឹកពីអច្ឆរិយៈភាពនិងការដឹងគុណទៅលើជីវិតដែលយើងមាននៅពេលនេះ ភ្លើងនៃកំហឹងនិងចិត្តលោភលន់នឹងលែងឆេះទៀតហើយ (នោះហើយដែលហៅថានិព្វានឬភាពស្ងប់ស្ងាត់)។

ព្រះស្ថាបនិកកៃសូសាម៉ាបានបញ្ចេញមតិជាក់ស្តែងចំពោះព្រះនិព្វាននិងភាពស្ងប់ស្ងាត់នេះ ដោយពាក្យថា "យើងស្រឡាញ់ និងថែរក្សាគ្នាទៅវិញទៅមក កាន់ដៃអ្នកដែលដើរយឺត ផ្តល់កម្លាំងដល់អ្នកដែលមិនមានហើយដើរជាមួយគ្នាប្រកបដោយតុល្យភាព។ ប្រសិនបើមនុស្សជាតិទាំងអស់អាចរស់នៅតាមរបៀបនេះយើងនឹងអាចទទួលបាននូវសន្តិភាពដ៏ធំធេងក្នុងជីវិតដ៏រស់រវើកប្រកបដោយភាពច្នៃប្រឌិត និងវឌ្ឍនភាព"។

ពឹងផ្អែកលើចិត្តរបស់យើងដែលប្រាថ្នាចង់បានបែបនេះយើងគោងតែរំពឹងលើបេះដូងយើង (បំភ្លឺខ្លួនដោយពន្លឺខ្លួនឯង) និងលើគោលការណ៍សមហេតុសមផលជាសាកល(បំភ្លឺខ្លួនឯងដោយពន្លឺព្រះធម៌) យើងត្រូវជួយអ្នកដែលពិបាកជាងនិងត្រូវនិយាយទៅកាន់អ្នកដែលមានបញ្ហាដែលនៅក្បែរយើងជាពិសេសបង្ហាញការយកចិត្តទុកដាក់ចំពោះស្ថានភាពរបស់មនុស្សដែលទោះជាមិនជាប់សាច់ឈាមអ្វីជាមួយយើងដោយធ្វើអ្វីដែលយើងអាចធ្វើបាន។

ព្រះស្ថាបនិកកៃសូសាម៉ាក៏បានប្រកូកប្រកាសថា "មុននឹងត្អូញត្អែរអំពីភាពងងឹតនៃបន្ទប់របស់យើង ចូរយើងចាប់ផ្តើមបើកបង្អួចដោយដៃរបស់យើង" ។ "ចូរយើងដែលជាអ្នកបានស្តាប់ការបង្រៀនប្រៀនប្រដៅរបស់ព្រះពុទ្ធផ្តួចផ្តើមគំនិតដើម្បីបើកបង្អួចនៃបេះដូងមនុស្ស។ចូរយើងលើកចង្កៀងនៃសេចក្តីបង្រៀនប្រៀនប្រដៅ (ព្រះធម៌) របស់ព្រះពុទ្ធឱ្យខ្ពស់ដើម្បីបំភ្លឺអន្ធការនៃភាពល្ងង់ខ្លៅ" ។ គ្មានវេលាណាដែលពាក្យទាំងនេះបន្លឺសម្លេងឱ្យឮខ្ទរខ្ទាំងជាងពេលនេះទេ។



From Kosei, November 2025

# Rissho Kosei-kai International

## Make Every Encounter Matter



## A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp